JAPAN INTERNATIONAL COOPERATION AGENCY

# ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

មករា - មីនា ២០២៣ • ភ្នំពេញ



## កម្មវិធីអ្នកស្ម័គ្រចិត្តជប៉ុនចៃកាបានត្រឡប់មកវិញហើយ



លោក ដាយចូ អ្នកស្ម័គ្រចិត្តផ្នែកវិទ្យាសាស្ត្រកំពុងធ្វើពិសោធន៍ពីការញែកសារធាតុរាវក្នុងស្រាក្រហម នៅគរុកោសល្យ និងវិក្រិតការខេត្តកំពង់ឆ្នាំង

ជាមួយនឹងលិខិតប្ដូរសាររវាងប្រទេសជប៉ុន និងប្រទេសស្នើសុំ តាំងពីឆ្នាំ ១៩៦៥ កម្មវិធីអ្នកស្ម័គ្រចិត្ត JICA បាននឹងកំពុងចូលរួមយ៉ាងសកម្មនៅក្នុង ៩៧ ប្រទេសជុំវិញពិភពលោក។

រហូតមកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាធ្លាប់បានទទួលអ្នកស្ម័គ្រចិត្តជប៉ុន ៧៩៧ នាក់ ឱ្យមកធ្វើការក្នុងប្រទេសកម្ពុជា ដើម្បីចែករំលែកបទពិសោធន៍ រស់នៅជាមួយប្រជាជនកម្ពុជា ដោយនិយាយភាសាខ្មែរ និង ដើម្បីទទួលយកបទពិសោធន៍ វប្បធម៌ និងប្រពៃណី ហើយជាធម្មតាត្រូវបានបញ្ជូនទៅកាន់បណ្ដាខេត្តផ្សេងៗក្នុងប្រទេសកម្ពុជា។

ដោយសារការរាតត្បាតនៃ COVID-19 អ្នកស្ម័គ្រចិត្ត JICA មិនត្រឹមតែអ្នកដែលស្ថិតក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងអ្នកស្ម័គ្រចិត្តជប៉ុននៅជុំវិញពិភពលោកត្រូវបានជម្លៀសទៅកាន់ប្រទេសជប៉ុនវិញ ហើយពួកគេមួយចំនួនត្រូវបញ្ចប់បេសកម្មរបស់ពួកគេពីចម្ងាយ។ ពេលនោះគឺជាពេលដែលសោកសៅបំផុតសម្រាប់ពួកគេ!

ទោះបីជាយ៉ាងណាក៏ដោយ ជាមួយនឹងការខិតខំប្រឹងប្រែងពីរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ អ្នកស្ម័គ្រចិត្តជប៉ុនអាចវិលត្រឡប់មកវិញបានដូចការគ្រោងទុក ហើយបច្ចុប្បន្នមានអ្នកស្ម័គ្រចិត្តចំនួន ២៦នាក់បាននឹងកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជាលើវិស័យផ្សេងៗគ្នា រួមមាន វិស័យអប់រំ និងកីឡា សុខាភិបាល ការវិភាគគុណភាពទឹក វិស្វកម្មអេឡិចត្រូនិច និងវិស្វកម្មសំណង់ស៊ីវិលនៅតាមបណ្ដាខេត្តសរុប ១០ ខេត្ត ក្រុង នៃប្រទេសកម្ពុជាដូចជា ភ្នំពេញ ខេត្តកណ្ដាល កំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពត និង ខេត្តស្វាយរៀង។

អ្នកស្ម័គ្រចិត្តភាគច្រើនស្ថិតនៅក្នុងវិស័យអប់រំ ធ្វើការរួមគ្នាជាមួយគ្រូដៃគូរសហការ ដើម្បីបង្កើនគុណភាពនៃការអប់រំ។

អ្នកស្ម័គ្រចិត្តក្នុងវិស័យសុខាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់អនាម័យ ព្រមទាំងផ្ដល់ការបណ្ដុះបណ្ដាលសម្រាប់ការសង្គ្រោះទារកទើបនឹងកើត ដែលវាជួយក្នុងការត្រួតពិនិត្យដង្ហើមដំបូងរបស់ទារក។

អ្នកស្ម័គ្រចិត្តជប៉ុនមកប្រទេសកម្ពុជា ដើម្បីផ្លាស់ប្ដូរចំណេះដឹង បទពិសោធន៍ និងផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសដល់ស្ថានប័នស្នើសុំអោយអស់ពីចិត្ត និងមិនបានរំពឹងអ្វីមកវិញឡើយ៕•

*ផ្នែកអ្នកស្ម័គ្រចិត្ត*

ទំព័រ ទី២ ទី៣ & ទី៤
**ព័ត៌មានអំពីគម្រោង**

សៀមរាបក្លាយជាទីក្រុងឆ្លាតវៃ



*រូបភាព Platform*

កិច្ចសហការលើសកម្មភាពមីនរវាងចៃកា និងស៊ីម៉ាក់



*ការចែករំលែកចំណេះដឹងផ្ទាល់របស់កម្ពុជាដល់ប្រទេសដែលរងផលប៉ះពាល់ដោយសារមីន*

ការពង្រឹងប្រព័ន្ធសុខាភិបាលឱ្យមានភាពធន់ទៅនឹងជំងឺកូវីដ ១៩ និង ជំងឺរាតត្បាតផ្សេងៗនាពេលអនាគត



*ទិដ្ឋភាពទូទៅនៃគម្រូរអាការសំណង់របស់មន្ទីរពេទ្យបង្អែក*

# ព័ត៌មានស្តីពីគម្រោង

មករា - មីនា ២០២៣ ●ភ្នំពេញ



## សៀមរាបក្លាយជាទីក្រុងឆ្លាតវៃ

### *បើកដំណើរការកិច្ចសហប្រតិបត្តិការបច្ចេកទេសថ្មីសម្រាប់ទីក្រុងឆ្លាតវៃនៅខេត្តសៀមរាប*




Source: JICA Survey Team

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ ឆ្នាំ២០១៨ ខេត្តសៀមរាបដែលជាទីក្រុងទេសចរណ៍ដ៏ទាក់ទាញបំផុតមួយក្នុងប្រទេសកម្ពុជា ត្រូវបានជ្រើសរើសជាទីក្រុងសាកល្បងនៃបណ្ដាញទីក្រុងឆ្លាតវៃអាស៊ាន (ASCN) ។

JICA បានសហការជាមួយរដ្ឋបាលខេត្តសៀមរាប ដើម្បីសម្រេចបាន"ទីក្រុងឆ្លាតវៃ" ចាប់តាំងពីឆ្នាំ២០២០។ នៅខែឧសភា ឆ្នាំ២០២០ "គម្រោងអនុវត្តវិធីសាស្រ្តទីក្រុងឆ្លាតវៃសម្រាប់ការដោះស្រាយបញ្ហាទីក្រុងក្នុងខេត្តសៀមរាប" ដែលជាគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់ JICA ត្រូវបានចាប់ផ្តើម ។ "វិធីសាស្រ្តទីក្រុងឆ្លាតវៃ"គឺជាគំនិតដែលស្វែងរកការដោះស្រាយបញ្ហានានាក្នុងទីក្រុងដោយប្រើបច្ចេកវិទ្យាឆ្លាតវៃ រួមជាមួយការគ្រប់គ្រងទីក្រុងដ៏សមស្រប និងការជឿទុកចិត្តរបស់ប្រជាជន ក្នុងដំណើរការអនុវត្ត និងការត្រួតពិនិត្យ/វាយតម្លៃ។ គម្រោងនេះត្រូវបានអនុវត្តរយៈពេលបីឆ្នាំ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវ និងពង្រឹងសមត្ថភាពមន្រ្តី ឱ្យក្លាយជា "ទីក្រុងឆ្លាតវៃ" ក្នុងខេត្តសៀមរាប ជាមួយនឹងចក្ខុវិស័យ "សម្រាប់ប្រជាជន និងអ្នកទស្សនា ជាមួយនឹងបេតិកភណ្ឌអង្គរ វប្បធម៌ខ្មែរ និងធម្មជាតិតាមរយៈដំណោះស្រាយដោយប្រើបច្ចេកវិទ្យាឆ្លាតវៃ និងឆ្ពោះទៅរកសង្គមទាក់ទាញ និងនិរន្តរភាព"។ គម្រោងនេះនឹងអនុវត្តសកម្មភាពសាកល្បង រួមមានការត្រួតពិនិត្យកន្លែងចតរថយន្តខុសច្បាប់ ការកែលម្អការប្រមូលសំរាម ការធ្វើឌីជីថលនៃស្ថិតិទេសចរណ៍ ការតាមដានឯកសារផ្ទៃក្នុងរបស់រដ្ឋាភិបាលការត្រួតពិនិត្យបរិស្ថានទីក្រុង និង ការសហការរវាងសាធារណៈ និង ឯកជនសម្រាប់វិស័យទេសចរណ៍ដើម្បីឆ្លុះបញ្ចាំងពីមេរៀន និងស្វែងយល់ពីផែនទីបង្ហាញផ្លូវ។

ដើម្បីលើកកម្ពស់ "ទីក្រុងឆ្លាតវៃ" ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការខ្លាំងពីសំណាក់សហគ្រាស រដ្ឋាភិបាល ស្ថាប័នអប់រំ និងសហគមន៍។ សហគ្រាសឯកជនដើរតួយ៉ាងសំខាន់ក្នុងការផ្តល់សេវាខណៈដែលរដ្ឋាភិបាលជួយសម្រួលដល់ដំណើរការទាំងមូល រួមទាំងការបង្កើតគោលនយោបាយ ច្បាប់ និងផែនការ និងការអនុវត្តគម្រោង។ ស្ថាប័នអប់រំ ក៏មានការរួមចំណែកយ៉ាងរឹងមាំ និងមានតួនាទីក្នុងការលើកកម្ពស់ការស្រាវជ្រាវ និង អភិវឌ្ឍន៍បច្ចេកវិទ្យាឆ្លាតវៃ ការអនុវត្ត និងការត្រួតពិនិត្យគម្រោង ដោយសហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀតក្នុង និងក្រៅប្រទេស។ ចុងក្រោយ ប្រជាជនគឺជាអ្នកទទួលផល ដែលពួកគេនឹងទទួលបទពិសោធន៍ផ្ទាល់ពី "ទីក្រុងឆ្លាតវៃ" ។ គម្រោងនេះនឹងចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាទីក្រុងតាមរយៈដំណើរការនៃការយល់ដឹងពីទីក្រុងឆ្លាត និងឈានដល់ការសម្រេចបាននូវ SDGs និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនក្នុងខេត្តសៀមរាប៕●

*ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ឧស្សាហ៍កម្ម*

## កិច្ចសហការលើសកម្មភាពមីនរវាងចៃកា និងស៊ីម៉ាក់

### *ការចែករំលែកចំណេះដឹងផ្ទាល់របស់កម្ពុជាដល់ប្រទេសដែលរងផលប៉ះពាល់ដោយសារមីន*

នៅពាក់កណ្តាលខែមករាអ្នកដោះមីនអ៊ុយក្រែន ចំនួន ៨រូប មកពីអង្គភាពផ្តល់សេវាកម្មរដ្ឋក្នុងគ្រាអាសន្នរបស់ប្រទេសអ៊ុយក្រែនបានមកប្រទេសកម្ពុជាហើយបានចូលរួមការបណ្តុះបណ្តាលលើការសម្អាតមីនពីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ។ការណ្តុះបណ្តាលផ្តោតលើប្រធានបទអមពីការប្រើប្រាស់ម៉ាស៊ីនរាវមីនដែលផលិតដោយប្រទេសជប៉ុន។តាមរយៈភាពជាដៃគូរនឹងគ្នាដ៏យូរអង្វែងរវាងចៃកា និងស៊ីម៉ាក់ក្នុងការសម្អាតមីនឥឡូវ CMACបានក្លាយជាអង្គការនាំមុខគេនៅលើសកលលោកក្នុងការវគ្គបណ្តុះបណ្តាលដល់ប្រទេសនានាដែលរងផលប៉ះពាល់ដោយសារ មីន ។ តាំងពីឆ្នាំ២០១២ មកស៊ីម៉ាក់បានផ្តលកម្មវិធីបណ្តុះបណ្តាលជាង ៣០ដល់ប្រទេស ចំនួន៥ ដែលមានអ្នកចូលរួមជាង៦០០នាក់បានរៀនពីបទពិសោធន៍របស់ស៊ីម៉ាក់។ JICAបច្ចុប្បន្នបាននឹងកំពុងជួយឧបត្ថម្ភស៊ីម៉ាក់ក្នុងការអភិវឌ្ឍសមត្ថភាពថែមទៀតដើម្បីផ្តល់នូវការបណ្តុះបណ្តាលប្រកបដោយគុណភាព នៅក្រោមគម្រោងបច្ចុប្បន្នដែលចាប់ផ្តើមពីខែតុលា ឆ្នាំ២០២០មក។ កម្ពុជានឹងបោសសម្អាតចំការមីនដែលស្គាល់ទាំងអស់អោយអស់ត្រឹមឆ្នាំ២០២៥ក្នុងនាមជារដ្ឋភាគីមួយនៃអនុសញ្ញាអូតាវ៉ា។ ទោះបីបើចំការមីនទាំងអស់ត្រូវបានសម្អាតក៏ដោយ CMACសង្ឃឹមថានឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកនូវបទពិសោធន៏ដ៏មានតម្លៃរបស់ខ្លួនដែលនឹងជួយក្នុងការដោះស្រាយបញ្ហាគ្រាប់មីននៅលើសកលលោក៕●

*ផ្នែកអភិវឌ្ឍន៍សង្គម និងអភិបាលកិច្ច*

JICA IN THE MEDIA

**"Industry ministry, JICA sign water supply agreement"**

https://phnompenhpost.com/national/industry-ministry-jica-sign-water-supply-agreement

ភ្នំពេញប៉ុស្ដិ៍
១៤ មករា ២០២៣

**"CMAC starts training Ukrainian deminers"**

https://www.khmer-timeskh.com/501219996/cmac-starts-training-ukrainian-demin-ers/

ខ្មែរថាមស៍
១៦ មករា ២០២៣

**"Cambodia, Japan provide tech training for Ukrainian deminers"**

https://www.phnompenhpost.com/national/cambodia-japan-provide-tech-training-ukrainian-deminers

ភ្នំពេញប៉ុស្ដិ៍
២៣ មករា ២០២៣

**"ព្រឹត្តការណ៍សំខាន់ៗនៅឆ្នាំ២០២៣សម្រាប់ចំណងមិត្តភាពយូរអង្វែងរវាងជប៉ុន-កម្ពុជា"**

ភ្នំពេញប៉ុស្ដិ៍
២៣ កុម្ភៈ ២០២៣

**"កម្ពុជាស្វែងរកជំនួយពី JICA ដើម្បីលើកកម្ពស់ផលិតកម្មកសិកម្មស្តង់ដារសម្រាប់ការនាំចេញ"**

កម្ពុជាស្វែងរកជំនួយពី JICA ដើម្បីលើកកម្ពស់ផលិតកម្មកសិកម្មស្តង់ដារសម្រាប់ការនាំចេញ -Khmer Times (khmer-timeskh.com)

ខ្មែរថាមស៍
១០ មីនា ២០២៣

ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

# ព័ត៌មានស្តីពីគម្រោង

មករា - មីនា ២០២៣ • ភ្នំពេញ



## ការពង្រឹងប្រព័ន្ធសុខាភិបាលឱ្យមានភាពធន់ទៅនឹងជំងឺ កូវីដ១៩ និង ជំងឺរាតត្បាតផ្សេងៗនាពេលអនាគត



*ទិដ្ឋភាពទូទៅនៃគម្រូរអាគារសំណង់របស់មន្ទីរពេទ្យបង្អែកខេត្តសៀមរាប*

ទីភ្នាក់ងារចៃកាបាននឹងកំពុងធ្វើការជាមួយសមភាគីកម្ពុជា លើការពង្រឹងប្រព័ន្ធសុខាភិបាល ដើម្បីសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកលត្រឹមឆ្នាំ២០៣០នៅក្នុងប្រទេសកម្ពុជា ដោយបន្តជួយគាំទ្រវិស័យសុខាភិបាលអស់ជាងបីទសវត្សរ៍មកហើយតាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ជំនួយឥតសំណង និងក្របខណ្ឌផ្សេងទៀត។មន្ទីរពេទ្យខេត្តសៀមរាប គឺជាមន្ទីរពេទ្យសាធារណៈ និង ជាមន្ទីរពេទ្យបង្អែកកម្រិតខ្ពស់នៅតំបន់ភាគពាយ័ព្យនៃប្រទេសកម្ពុជា ដែលផ្តល់នូវសេវាវេជ្ជសាស្រ្តពិសេស និងទូទៅ។ អ្នកជំងឺដែលមកសម្រាកព្យាបាលនៅមន្ទីរពេទ្យនេះ មិនត្រឹមតែជាអ្នកខេត្តសៀមរាបប៉ុណ្ណោះទេ គឺមានអ្នកជំងឺដែលមកពីបណ្តាខេត្តជិតខាងផងដែរ។ ថ្មីៗនេះ អ្នកជំងឺមិនឆ្លង(NCDs) និងអ្នកជំងឺដែលមានរបួសរាងកាយមានការកើនឡើងដោយសារការឆ្លងជំងឺ និងការកើនឡើងនៃគ្រោះថ្នាក់ចរាចរណ៍។ ប៉ុន្តែមន្ទីរពេទ្យមិនអាចផ្តល់សេវាវេជ្ជសាស្រ្តបានគ្រប់គ្រាន់នោះទេព្រោះកន្លែងសម្រាកព្យាបាល និងឧបករណ៍វេជ្ជសាស្រ្តសម្រាប់ធ្វើការវិភាគ និងព្យាបាលនៅមានកំណត់នៅឡើយ។ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃតម្រូវការសេវាវេជ្ជសាស្រ្ត ទីភ្នាក់ងារចៃកាបានផ្តល់នូវជំនួយឥតសំណងលើ" គម្រោងកែលម្អមន្ទីរពេទ្យខេត្តសៀមរាប "ក្នុងគោលបំណងជួយសាងសង់អគារថ្មីមួយដែលមានកម្ពស់ ៤ ជាន់ មានទំហំប្រមាណ ៨,៤៥៩ម៉ែត្រការ៉េ, នៃផ្ទៃដីសរុប និងមានគ្រែចំនួន ២១២ រួមទាំងគ្រែសម្រាប់បន្ទប់សង្គ្រោះបន្ទាន់ (ICU) ចំនួន ២៣ នៅផ្នែកអ្នកជំងឺក្រៅ ផ្នែកសង្គ្រោះបន្ទាន់ ក៏ដូចជាផ្នែកវះកាត់នៅក្នុងបរិវេណនៃមន្ទីរពេទ្យខេត្តសៀមរាប។ បន្ថែមពីលើការសាងសង់អគារថ្មីនេះ គម្រោងនឹងផ្តល់ឧបករណ៍វេជ្ជសាស្រ្តមួយចំនួនបន្ថែមទៀតដូចជា ម៉ាស៊ីនស្កានែរ (CT-Scan), ម៉ាស៊ីនថតឆ្លុះកាំរស្មីអិចចល័ត, ម៉ាស៊ីនតាមដានសភាពអ្នកជំងឺ និងម៉ាស៊ីនវិភាគឧស្ម័នក្នុងឈាម ជូនដល់មន្ទីរពេទ្យ។ លើសពីនេះ គោលបំណងពង្រឹងសមត្ថភាពសេវាវេជ្ជសាស្រ្តរបស់មន្ទីរពេទ្យបង្អែកស្រុកចំនួន ៤ ផ្សេងទៀត ដោយផ្តល់ជាឧបករណ៍វេជ្ជសាស្រ្តជាមូលដ្ឋានមួយចំនួនផងដែរ។ គម្រោងនេះមានទឹកប្រាក់សរុបចំនួន ២,១៥៣ លានយ៉េនជប៉ុន ប្រមាណជា១,៨៩៥លានដុល្លាអាមេរិច ។ ការងារសាងសង់មន្ទីរពេទ្យនេះបានចាប់ផ្តើមកាលពីខែធ្នូ ឆ្នាំ ២០២១ ហើយរំពឹងថានឹងត្រូវបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០២៣។ ទីភ្នាក់ងារចៃកា សង្ឃឹមថាសេវាវេជ្ជសាស្រ្ត និងការពង្រឹងប្រព័ន្ធសុខាភិបាលនៅក្នុងខេត្តសៀមរាប និងខេត្តដែលនៅជុំវិញនោះមានភាពប្រសើរឡើង តាមរយៈគម្រោងនេះ ហើយក៏រំពឹងផងដែរថានឹងរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍កបដោយនិរន្តរភាព (SDGs) ៣ និង ១១ ហើយនឹងត្រូវបានផ្សារភ្ជាប់ជាមួយនឹងគម្រោងកែលម្អមន្ទីរពេទ្យខេត្តទៅជាមន្ទីរពេទ្យថ្នាក់តំបន់ ដើម្បីលើកកម្ពស់ប្រព័ន្ធសេវាថៃទាំសុខភាព និងសំណង់អាគារសុខភាពកាន់តែល្អប្រសើរឡើងនៅកម្រិតអប្បបរមា ដែលបត់បែនទៅនឹងជំងឺកូវីដ១៩ និងជំងឺរាតត្បាតផ្សេងទៀតនាពេលអនាគត ក៏ដូចជាបម្រើដល់ប្រជាជនទូទៅ ដើម្បីកាត់បន្ថយភាពខុសគ្នាក្នុងតំបន់នៃសេវាវេជ្ជសាស្រ្តកម្រិតខ្ពស់ និងការប្រមូលផ្តុំអ្នកជំងឺមិនឆ្លង (NCD) ដែលពាក់ព័ន្ធទាំងអស់នៅក្នុងមន្ទីរពេទ្យថ្នាក់ជាតិផងដែរ៕●

*ផ្នែកអភិវឌ្ឍន៍សង្គម*

ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

ព័ត៌មានអន្តរជាតិ

មករា - មីនា ២០២៣ •ភ្នំពេញ

# ទីប្រឹក្សាពិសេសរបស់ចៃកា លោកគីតៅកាបានជួបសម្តែងការគួរសម និងជជែកពិភាក្សាជាមួយនាយករដ្ឋមន្ត្រីកម្ពុជា សម្តេចហ៊ុន សែន

កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ ខណៈពេលដែលធ្វើទស្សនកិច្ចសិក្សានៅកម្ពុជាទីប្រឹក្សាពិសេសរបស់ចៃកា (អតីតនាយកចៃកា) លោកគីតៅកា ស៊ីនីជី បានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែននាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែនបានវាយតម្លៃខ្ពស់ពីតួនាទីរបស់ជប៉ុន ក្នុងការចរចាស្វែងរកសន្តិភាព និងអភិវឌ្ឍន៍នៅកម្ពុជាដែលក្នុងនោះក៏មានទស្សនកិច្ចចំនួន ៥លើករបស់នាយករដ្ឋមន្ត្រីជប៉ុន ដែលបានចាប់ផ្តើមតាំងពីទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រី Obuchi Keizon កាលពីឆ្នាំ២000។ ខណៈដែលលើកឡើងអំពីគម្រោងជាក់លាក់ ដូចជាគម្រោងធ្វើឱ្យប្រសើរឡើងនូវផ្លូវជាតិលេខ១, គម្រោងកសាងស្ពានអ្នកលឿង និងគម្រោងកសាងស្ពានឆ្លងទន្លេមេគង្គ សម្តេចនាយរដ្ឋមន្ត្រីក៏បង្ហាញការដឹងគុណដល់ កិច្ចសហការរបស់ចៃកាកន្លងមក។ បណ្ឌិត គីតៅកា បានណែនាំប្រធានចៃកា ផ្នែកកម្មវិធីសម្រាប់ការសិក្សាអំពីជប៉ុនដែលលោកបានបង្រៀនលើប្រធានបទមួយឈ្មោះ Meiji Restoration៖ ចាប់ផ្តើមធ្វើទំនើបកម្មដ៏ពេញលេញក្នុងនោះ លោកបានផ្តល់ការធ្វើបទបង្ហាញនៅវិទ្យាស្ថានការទូត និងទំនាក់ទំនងអន្តរជាតិ (NIDIR) កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ កន្លងទៅនេះ។ ជាងនេះទៅទៀត លោកបានធ្វើការកត់សម្គាល់ថា កត្តាជោគជ័យនៃMeiji Restoration ដោយមានការទទួលស្គាល់ជាចំបងរបស់ជប៉ុនអំពីសារៈសំខាន់សម្រាប់សន្តិភាព និងស្ថេរភាពក្នុងការអភិវឌ្ឍជាតិ ហើយជាការពិតដែលមានមន្ត្រីរដ្ឋាភិបាលដែលមានសមត្ថភាព រួមទាំងអ្នកនយោបាយដែលកំពុងធ្វើការទៅលើបញ្ហាសំខាន់ៗសម្រាប់ជាតិ ។បណ្ឌិតគីតៅកា ក៏បានចាប់អារម្មណ៏ ទៅលើការគាំទ្ររបស់លោកសម្រាប់រដ្ឋាភិបាលកម្ពុជា ដែលគាំទ្រការប្រឆាំងនឹងការឈ្លានពាន របស់ប្រទេសរុស្ស៊ី លើទឹកដីអ៊ុយក្រែន ហើយលោកក៏បានសង្កត់ធ្ងន់ថា នៅក្នុងស្ថានភាពពិភពលោកបច្ចុប្បន្ន គឺជប៉ុនត្រូវការដើរតួនាទី សកម្មជាងមុនដើម្បីស្វែងរកសាមគ្គីភាពជាមួយប្រទេសដ៏ទៃ ជាពិសេសប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍


ទិដ្ឋភាពក្នុងកិច្ចប្រជុំ

ដែលបានចែករំលែកនូវគុណតម្លៃ ដូចជាសេរីភាព និងនិតិរដ្ឋ។ ជាកិច្ចបញ្ចប់ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន បានសម្តែងការដឹងគុណដល់ប្រទេសចំនួនបួន សម្រាប់ការផ្តល់វ៉ាក់សាំងដល់កម្ពុជាមានដូចជាប្រទេសជប៉ុន សហរដ្ឋអាមេរិច អូស្ត្រាលី និងប្រទេសឥណ្ឌា ហើយសម្តេចក៏បានបង្ហាញនូវការរំពឹងទុករបស់គាត់ក្នុងការពង្រឹងទំនាក់ទំនងជាមួយប្រទេសជាដៃគូ។ កិច្ចប្រជុំបានផ្តោតលើរបៀបវារៈជាច្រើន ហើយក៏បានចំណាយពេលជជែកគ្នាលើសពេលវេលាដែលបានគ្រោងទុក៕•

https://www.jica.go.jp/english/news/field/2022/20220929_10ey.html

## លោកប្រធាន តាណាកា បានផ្លាស់ប្តូរការយល់ឃើញជាមួយប្រតិភូមកពីស្ថាប័នសេវាសង្គ្រោះបន្ទាន់នៃសាធារណៈរដ្ឋអ៊ុយក្រែន៖ កិច្ចសហការក្នុងការលើកម្ពស់សមត្ថភាពសម្រាប់សកម្មភាពមនុស្សធម៌សម្អាតមីន

ជាកិច្ចចាប់ផ្តើម លោកប្រធានតាណាកា បានសម្តែងការរំលែកទុក្ខដល់ជនរងគ្រោះ ក្នុងឧប្បត្តិហេតុធ្លាក់យន្តហោះនៅប្រូវ៉ារី កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ដែលមានលោកម៉ូណាស់ស្ទីហ្សគី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃរបស់អ៊ុយក្រែន។ បន្ទាប់មកលោកប្រធាន បានសំដែងការដឹងគុណដល់អ្នកដោះមីនទាំងអស់មកពីស្ថាប័នសេវាសង្គ្រោះបន្ទាន់ នៃសាធារណៈរដ្ឋអ៊ុយក្រែន ដែលបានយកអាយុជីវិតទៅប្តូរក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន ដើម្បីការពារជីវិត និងការពារសុវត្ថិភាពរបស់ប្រជាជនអ៊ុយក្រែន ហើយលោកក៏បានបញ្ជាក់អំពីឆន្ទៈរបស់ចៃកា ក្នុងការគាំទ្រជាបន្ទាន់នូវការអភិវឌ្ឍសមត្ថភាពស្ថាប័នសេវា សង្គ្រោះបន្ទាន់របស់អ៊ុយក្រែន ក្នុងសកម្មភាពមនុស្សធម៌ កំចាត់មីន។ លោកក៏បានលើកឡើងផងដែរថា ការឈ្លានពានរបស់ប្រទេសរុស្ស៊ី ទៅលើប្រទេសអ៊ុយក្រែន គឺបានរំលោភយ៉ាងច្បាស់ទៅលើច្បាប់អន្តរជាតិ ហើយវាជាការប្រឈមដល់របៀបរៀបរយសាកល ដូច្នេះហើយសកម្មភាពរបស់ស្ថាប័នសេវាសង្គ្រោះបន្ទាន់របស់អ៊ុយក្រែនគឺមិនត្រឹមតែសុវត្ថិភាព និងសន្តិសុខសម្រាប់ប្រជាជនអ៊ុយក្រែនប៉ុណ្ណោះទេ តែវាក៏បានជួយការពារដល់ សណ្តាប់ធ្នាប់សាកលនេះដែរ។ លោកប្រធាន បានបន្ថែមទៀតថា ការចូលរួមរបស់ស្ថាប័នសេវាសង្គ្រោះបន្ទាន់របស់អ៊ុយក្រែនក្នុងវគ្គបណ្តុះបណ្តាលកំរិតខ្ពស់ស្តីអំពី ប្រព័ន្ធនៃការរុករកមីន (Advance Landmine Imagine System, ALIS) នៅមជ្ឈមណ្ឌលសកម្មភាពមីននៅកម្ពុជា ពីថ្ងៃទី១៦ ដល់ ២០ ខែមករា ឆ្នាំ២០២៣ គឺមានសារសំខាន់ក្នុងចលនាសហប្រតិបត្តការណ៍នៅអាស៊ីដើម្បីគាំទ្រដល់ប្រទេសអ៊ុយក្រែន៕•

https://www.jica.go.jp/english/news/field/2022/20230131_10y.html

### ទំនាក់ទំនងយើង

**ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា** គឺជាព្រឹត្តិប័ត្រប្រចាំឆមាស ដែលផ្តោតលើទស្សនវិស័យអន្តរជាតិរបស់ JICA និងការរួមចំណែករបស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក។ ព្រឹត្តិប័ត្រព័ត៌មាននេះរៀបរាប់អំពីការងាររបស់ JICA ក្នុងប្រទេសកម្ពុជា។

**ការិយាល័យចៃកាប្រចាំនៅកម្ពុជា**

ជាន់ទី ១៦&១៧, អាគារ Keystone, #១៤៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ៖ +855-(0) 23-238 050

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) គឺជាទីភ្នាក់ងារជំនួយទ្វេភាគីធំជាងគេបំផុតនៅលើពិភពលោកដែលផ្តល់នូវជំនួយផ្សេងគ្នាជាច្រើនទម្រង់នៅប្រទេសជាង ១៥០ ជុំវិញពិភពលោក។

ស្វែងរកយើងខ្ញុំនៅទីនេះ!

គេហទំព័រ ហ្វេសប៊ុក